**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**អគ្គនាយកដ្ឋានកសិកម្ម**

លេខ...១២៩២...អ.ន.ក

ថ្ងៃ.ចន្ទ.....១២ កើត...ខែ.ស្រាពណ៍ ឆ្នាំ.ច...សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី....០៨....ខែ..សីហា.......ឆ្នាំ២០១៨

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ៖** របាយការណ៍ស្តីពីសកម្មភាពអនុវត្តការងារប្រចាំខែកក្កដា ឆ្នាំ២០១៨ របស់អគ្គនាយកដ្ឋានកសិកម្ម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតរាយការណ៍ជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាប នូវលទ្ធផលអនុវត្តសកម្មភាពការងាររបស់អគ្គនាយកដ្ឋានកសិកម្មប្រចាំខែកក្កដា ឆ្នាំ២០១៨ មានដូចខាងក្រោម៖

I. **លទ្ធផលបង្កបង្កើនផលកសិកម្មរដូវវស្សាឆ្នាំ២០១៨** (គិតត្រឹមថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៨)

**១. ដំណាំស្រូវ** : ផ្ទៃដីស្ទូងព្រោះសរុបអនុវត្តបានចំនួន ២.១២១.៧២៥ ហ.ត ស្មើនឹង៨៤,៤០ % នៃផែនការ ចំនួន ២.៥១៣.៨៩៥ ហ.ត លឿនជាងឆ្នាំមុនចំនួន ២៦៨.៨៨០ ហ.ត

- ការងារភ្ជួររាស់ដី : ផ្ទៃដីភ្ជួររាស់សរុបអនុវត្តបានចំនួន២.៣៩២.៥៧៥ហ.ត លឿនជាងឆ្នាំមុនចំនួន ៦២.៦៥៤ ហ.ត ក្នុងនោះផ្ទៃដីភ្ជួររាស់ដោយគ្រឿងយន្តចំនួន២.៣១៧.១៥៤ ហ.ត ស្មើនឹង៩៦,៨៤% នៃផ្ទៃដីភ្ជួររាស់សរុប
- ផ្ទៃដីសាបសរុប : ២៨.៩៧៨ ហ.ត យឺតជាងឆ្នាំមុនចំនួន ៥.៦៤១ ហ.ត។







*ក្រាហ្វិក៖ ស្ថិតិផ្ទៃដីភ្ជួររាស់ និងដាំដុះស្រូវរដូវវស្សាពីឆ្នាំ២០១៤-២០១៨ គិតត្រឹម ចុងខែកក្កដានៃឆ្នាំ*

តាមក្រាហ្វិកខាងលើបង្ហាញថា ក្នុងរយៈពេល៥ឆ្នាំដូចគ្នាគិតត្រឹមចុងខែកក្កដាផ្ទៃដីភ្ជួររាស់ និងការងារដាំដុះរដូវវស្សាឆ្នាំ២០១៨ មានចំនួនច្រើនជាងបណ្តាឆ្នាំមុនៗ បើប្រៀបធៀបរយៈពេល៥ឆ្នាំចុងក្រោយ។

**២. ដំណាំរួមផ្សំ** : អនុវត្តបានចំនួន ៣០.៩៥៥ ហ.ត លឿនជាងឆ្នាំមុនចំនួន ១.៣២៤ ហ.ត។

**៣. ដំណាំឧស្សាហកម្ម** : អនុវត្តបានចំនួន ៨៤៧.២០០ ហ.ត លឿនជាងឆ្នាំមុនចំនួន ៩០.៧១៨ ហ.ត។



អាសយដ្ឋានលេខ: ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ:(០២៣) ៨៨៣ ៤២៧ ទូរសារលេខ:(០២៣) ៨៨៣ ៤២៧
Address # 54B/49F, Street 395-656, Sangkat Toeuk Laak 3, Khan Tuol Kok, Phnom Penh. Cambodia, Phone : (023) 883 427, Fax : (023) 883 427